# ព្រះរាជក្រឹត្យ

នស/រកត/០៨០០/១៥២

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.**–

បង្កើតអាជ្ញាធរជាតិមួយសម្រាប់ទទួលបន្ទុករៀបចំ និងអភិវឌ្ឍន៍គោលនយោបាយ សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដើម្បីជំរុញអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាហៅថា អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា(National Information Communications Technology Department Authority ) ដែលមានសមាសភាពដូចតទៅនេះ ៖

១- សម្តេច **ហ៊ុន សែន** ជាប្រធាន

២- ឯកឧត្តម **សុខ អាន** ជាអនុប្រធាន

៣- ឯកឧត្តម **ដាន់ ភិន** ជាអនុប្រធាន

៤- ឯកឧត្តម **ម៉ាន សុវត្ថិ** ជាសមាជិក

៥- ឯកឧត្តម **តូ លីវុឌ្ឍ** ជាសមាជិក និងជាអគ្គលេខាធិការ
មានឋានៈស្មើអនុរដ្ឋលេខាធិការ

**មាត្រា ២.**–

អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា មានភារកិច្ច ៖

– រៀបចំគោលនយោបាយសម្រាប់រយៈពេលខ្លី មធ្យម និងវែងដើម្បីជំរុញការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា។
– អនុវត្តន៍គោលនយោបាយជំរុញការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដើម្បីជំរុញការអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចជាតិជាអតិបរមា។
– ពិនិត្យ តាមដាន និងធ្វើសវនកម្មលើរាល់កិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។

**មាត្រា ៣.**–

អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ៤.**–

អគ្គលេខាធិការរង សមាជិក និងក្រុមការងារជំនាញដទៃទៀត នឹងកំណត់តែងតាំងតាមគោលការណ៍ច្បាប់ជាធរមាន តាមសំណើរបស់ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។

**មាត្រា ៥.**–

អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា មានសិទ្ធិប្រើប្រាស់ត្រាទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់សំរបសំរួលការងារ។ សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៦.**–

ការចំណាយទាំងអស់សម្រាប់បំរើឱ្យសកម្មភាពរបស់ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងថវិកាដែលទទួលបានពីការឧបត្ថម្ភទ្វេភាគី ឬពហុភាគី ។

**មាត្រា ៧.**–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.–**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៩.–**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

លេខ: ១៦៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន់**